ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បណ្ណាល័យអនុវត្តបច្ចេកវិទ្យា

# ការចិញ្ចឹម និងគ្រប់គ្រងទានៅជនបទ



រៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

សហការជាមួយ នាយកដ្ឋានផលិតកម្ម និងបសុពេទ្យាបាល

ឧបត្ថម្ភដោយ គំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី

**រៀបរៀងដោយៈ បណ្ឌិត ខៀវ បូរិន**
**មជ្ឈមណ្ឌលអភិវឌ្ឍន៍ការចិញ្ចឹមសត្វ និងកសិកម្ម “សែលអាគ្រីត”**
ទូរស័ព្ទៈ ០២៣ ២២៣៦៤០
អ៊ីម៉ែលៈ celagrid@celagrid.org

**កាលបរិច្ឆេទៈ ខែ កក្កដា ឆ្នាំ ២០០៦**

© រក្សាសិទ្ធិគ្រប់យ៉ាងៈ គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

## បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹងស្ថាប័ន និង ប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជាបានខិតខំយ៉ាងពេញទំហឹង ដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាម គោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការវិភាគប្រព័ន្ធកៀស្ត្រ-បរិស្ថាន ថ្នាក់ឃុំ សង្កាត់ និង បានចងក្រងជាបទដ្ឋានអនុវត្តបច្ចេក វិទ្យានេះឡើង។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះបានចងក្រងដោយអ្នកជំនាញឯកទេស (Subject Matter Specialist) នឹង ត្រូវបានឆ្លងការពិនិត្យពិគ្រោះយោបល់ និង ឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាព មកពីនាយកដ្ឋានជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗ ទៀត។ ឯក សារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពីព័តិមាន បច្ចេកទេស វិធីសាស្ត្រ នីតិវិធី និង ផែនការថវិកាចំណាយសម្រាប់ជួយដល់ មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយក ទៅប្រើប្រាស់ ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័តិមាន និងបច្ចេកវិទ្យាកសិកម្មតាម គ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និង ផលិតករដែលរស់នៅក្នុងតំបន់មានសក្តានុពលភាពស្របតាម លក្ខខ័ណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅមូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្ម កសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និង បង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់ បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជា ឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាលភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និង អ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និងទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម។

**រដ្ឋមន្ត្រី**

## អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ (បទដ្ឋានអនុវត្តបច្ចេកវិទ្យា)។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យាដើម្បីជួយដោះស្រាយបញ្ហាផ្នែកកសិកម្មរបស់កសិករ ។បអបផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់ឱ្យមន្ត្រីផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យានេះទៅកសិករ ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និង ខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការ ក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗទៀតដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៏កសិកម្មនៅតាមមូលដ្ឋានប្រើប្រាស់ ។

បអប មានលក្ខណៈដូចខាងក្រោមនេះ ៖

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករតាមរយៈប្រភពជាច្រើនដូចជា ប្រព័ន្ធគ្រប់គ្រងព័តិមានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម(FSMIS) ដែលផ្ទុកនូវព័ត៌មានសំខាន់ៗរបស់កសិករ ។ បញ្ហាផ្នែកកសិកម្មរបស់កសិករ ត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បអប មាននៅតាមស្ថាប័ននានាដូចខាងក្រោមៈ

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមការងារ បអប បន្ទាប់មកអនុម័តនិងអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន ។

## ១. សេចក្តីអធិប្បាយ

**សេចក្តីសង្ខេប**

**បញ្ហា** អាត្រារស់ទាបពេលទានៅតូចៗ និងផលិតកម្មស៊ុតទាប

**គោលបំណង** ផលិតកូនទាមានសុខភាពល្អសម្រាប់ចិញ្ចឹមរហូតដល់ដំណាក់កាលផលិតស៊ុត និងការពារពី ជំងឺផ្សេងៗ ។

**វិធីសាស្ត្រ**

១. ជ្រើសរើសកូនទាដែលមានសុខភាពល្អ

២. បង្កាត់ទាសម្រាប់ផលិតសាច់ និងស៊ុតបានខ្ពស់

៣. ផ្តល់ការថែទាំចាប់ពីដំណាក់កាលកូនទារហូតដល់ទាពង

៤. រៀបចំចំណីបានល្អ

៥. ធ្វើការគ្រប់គ្រងបានប្រសើរ តាមដំណាក់កាលនៃអាយុរបស់ទា

**គោលបំណង និងផលប្រយោជន៍**

- ផ្តល់ដល់ភ្នាក់ងារផ្សព្វផ្សាយនូវការណែនាំបច្ចេកទេស និងផ្សព្វផ្សាយសាមញ្ញ និងសមរម្យដើម្បីឱ្យផ្ទេរព័ត៌មាន-សារដល់កសិករសម្រាប់កែលំអផលិតកម្មមាន់ក្នុងស្រុកនៅជនបទ។
- ផ្តល់ដល់ភ្នាក់ងារផ្សព្វផ្សាយនូវជម្រើសបច្ចេកទេស អាស្រ័យទៅតាមលក្ខខណ្ឌ និងធនធានដែលមាននៅតាមតំបន់នីមួយៗ និង។
- ភ្នាក់ងារផ្សព្វផ្សាយអាចប្រើប្រាស់ បអប ‘TIP’នេះដើម្បីបង្កើនចំណូលសេដ្ឋកិច្ចគ្រួសារកសិករតាមរយៈការកែលំអចំណី ការគ្រប់គ្រង និងថែទាំទា ។

**លក្ខណៈវិនិច្ឆ័យបច្ចេកទេសសមស្រប:**

ខាងក្រោមនេះ ជាលក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តន៍ បអប ‘TIP’នេះ ដើម្បីសំរេចជោគជ័យលើទិសដៅលើកឡើងលើ។

**ផែនដី:**

- ករណី ហ្វូងទា ៣០-៣៥ ក្បាល អាចទទួលខុសត្រូវក្នុងការថែទាំ តែនៅពេលដែលហ្វូងទាមានចំនួន ១០០-១៥០ក្បាល បុរសអាចចូលរួមក្នុងការសាងសង់ទ្រុង ។

**អាកាសធាតុ/ទឹក**

- ទាអាចចិញ្ចឹមនៅគ្រប់ពេលវេលា និងរដូវ ប៉ុន្តែគួរចាប់ផ្តើមចិញ្ចឹមនៅដើមរដូវវស្សា ដោយសារមានចំណី ជាពិសេសរុក្ខជាតិដុះក្នុងទឹក កូនក្តាម ខ្យង នៅតាមប្រឡាយ និងថ្លុកក្បែរផ្ទះ ។
- ទាត្រូវការទឹកសម្រាប់ហែលលេង ហើយនៅក្នុងពេលតែមួយ ពួកវាអាចរកចំណីនៅក្នុងទឹក ។

**ភូមិសាស្ត្រ**

- បអប 'TIP' នេះអាចយកទៅអនុវត្តនៅគ្រប់ទីកន្លែងទាំងអស់នៃប្រទេសកម្ពុជា លើកលែងតែតំបន់ខ្ពង់រាប ដូចជាតំបន់ភ្នំនៅភាគឦសានដែលគ្មានទឹកគ្រប់គ្រាន់តែពួកគេអាចចិញ្ចឹមទាកាប៉ា ។

**ទំហំទីកន្លែង**

- ការចិញ្ចឹមទាជាលក្ខណៈគ្រួសារ តំរូវការផ្ទៃដី ៣-៤ ម២ សម្រាប់កូនទា ៣០-៣៥ ក្បាល និង ១៥ម២ សម្រាប់ទាសាច់ ឬទាពង។ ដោយសារជំងឺផ្តាសាយបក្សី ទាគួរដាក់ទ្រុង (ជីវសន្តិសុខ) ជៀសវាងទំនាក់ទំនងជាមួយសត្វផ្សេងទៀត ជាពិសេសបក្សីព្រៃ ។ កន្លែងផ្តល់ចំណីទាជាទូទៅទាក់ទាញសត្វស្លាបដទៃ ឱ្យចុះមកស៊ីចំណីដែរ ។

**តំរូវការពលកម្ម**

- មនុស្សម្នាក់នៅក្នុងគ្រួសារ ប្រសើរជាស្ត្រីចំណាយពេល១ម៉ ក្នុង១ថ្ងៃ ដាក់ទឹក-ចំណី សំអាត និងការងារបន្ទាប់តិចតួច។ ការថែទាំកូនទាអាចតំរូវការពលកម្មច្រើន រួមបញ្ចូលទាំងការផ្តល់ កំដៅកូនទាសំអាតទ្រុង និងផ្តល់ចំណី ។ បុរសអាចជួយការងារនៅពេលសាងសង់ទ្រុង ។

**ស្ថានភាពកសិករអនុវត្ត បអប 'TIP' នេះ**

- ដើម្បីធ្វើឱ្យការចិញ្ចឹមទាទទួលប្រាក់ចំណេញច្រើនកសិករគួរចាប់ផ្តើមចិញ្ចឹមកូនទានៅដើមរដូវវស្សា ។

- ថវិកាចំណាយក្នុងការចិញ្ចឹម គឺ ១៥០.០០០-២០០.០០០ រៀល សម្រាប់កូនទា ៣០-៣៥ ក្បាល រហូតដល់អាយុ ៣ខែ ។ សម្រាប់ការចិញ្ចឹមទាពង កសិករត្រូវការចំណាយ ១,៣ លានរៀល ក្នុងមួយឆ្នាំ ដែលអាចទទួលចំណូលមកវិញ ២,៤ លានរៀល ក្នុងមួយឆ្នាំ ។

**អនុសាសន៍ផ្សេងទៀត**

- ទាពូជក្នុងស្រុក និងទាកាប៉ា សមស្របសម្រាប់ការចិញ្ចឹមជាលក្ខណៈគ្រួសារ ។ កូនទាអាចរកទិញបាននៅគ្រប់តំបន់ តែកូនទាកាប៉ា កសិករអាចឱ្យមេវាភ្ញាស់នៅតាមភូមិ ។

## ២. ការណែនាំបច្ចេកទេស

### ២.១ ហេតុផលនៃការបង្កើត បអប 'TIP'

ជាទំលាប់កសិករចិញ្ចឹមទាជាលក្ខណៈគ្រួសារនៅជនបទ ។ ពួកគេចិញ្ចឹមទាសម្រាប់យកពង ដោយទុកទាឈ្មោលមួយចំនួនសម្រាប់បង្កាត់ពូជ ហើយទាឈ្មោលផ្សេងទៀតសម្រាប់យកសាច់បរិភោគក្នុងគ្រួសារ ។ កសិករជាធម្មតាទុកទាឈ្មោល ២-៣ក្បាល នៅក្នុងហ្វូងសម្រាប់មេទា ២០-៣០ក្បាល ។ កសិករអាចរកកូនទាតាមប្រភពផ្សេងៗ ដូចជាផ្សារ កន្លែងភ្ញាស់ពងទានៅតាមភូមិ និងកូនទាដែលភ្ញាស់ដោយមេមាន់ ឬទាកាប៉ានៅតាមផ្ទះ ។

ដើម្បីធ្វើឱ្យការចំណាយលើចំណីទាប កសិករប្រើយុទ្ធសាស្ត្រផ្សេងៗដើម្បីចិញ្ចឹមទា ។ កសិករចិញ្ចឹមកូនទាអាយុ ១អាទិត្យ ដាក់ទ្រុង ដោយឱ្យវាស៊ីកន្ទក់ ចកបាយទា ជន្លេន ។ល។ តែនៅពេលកូនទា មានអាយុ ២-៣អាទិត្យ ពួកគេបង្ហាត់វាឱ្យហែលទឹកនៅតាមវាលស្រែ និងប្រឡាយនៅក្បែរផ្ទះដែលនៅ ពេលជាមួយគ្នាពួកវាអាចស៊ីកូនក្តាម ខ្យង និងរុក្ខជាតិដុះក្នុងទឹក។ នៅពេលដែលទាធំល្មមកសិករលែងពួកវា ឱ្យរកចំណីនៅក្នុងស្រែ។ សំខាន់ជាងនេះទៅទៀតកសិករលែងឱ្យទាដើរស៊ីចំណីក្រោយពេល ច្រូតកាត់រួចដោយ ពួកវារើសគ្រាប់ស្រូវសេសសល់នៅក្នុងស្រែ ។ កសិករអាចចិញ្ចឹមទាឱ្យប្រសើរជាងនេះដោយចិញ្ចឹមដាក់ទ្រុង ហើយឱ្យចំណីដែលគេមាននៅតាមភូមិការចិញ្ចឹមបែបនេះធ្វើឱ្យទាឆាប់ធំនិងសំខាន់ទៅទៀតនោះការចូលរួមចំណែកការពារជំងឺជាពិសេសការផ្ទុះឡើងនៃជំងឺផ្តាសាយបក្សី ។

## ២.២ ការជ្រើសរើសពូជ

មានពូជទាជាច្រើននៅប្រទេសកម្ពុជា រួមបញ្ចូលទាពូជក្នុងស្រុក និងនាំចូល ។ ពូជទាទាំងនោះមាន ទាសំពៅ អង្កាម និងកាប៉ា។ ប៉ុន្មានឆ្នាំចុងក្រោយនេះពូជទា កាគីកាំបែល និងទាប៉េកាំងត្រូវបាននាំចូលមកចិញ្ចឹមយកស៊ុត និងសាច់នៅប្រទេសកម្ពុជា។ ពូជទាំងពីរនេះភាគឃើញមានចិញ្ចឹមនៅកសិដ្ឋានធំៗ។ ទោះបីយ៉ាងណាក៏ដោយកសិករគួរបន្តការចិញ្ចឹមទាពូជក្នុងស្រុកដូចជាទាសំពៅ អង្កាម និងកាប៉ា និងទាកូនកាត់ជាមួយទានាំចូល ។ ប្រសិនបើការចិញ្ចឹមគ្រាន់ តែសម្រាប់ការផលិតសាច់នោះទេទាពូជក្នុងស្រុកនិងទាកាប៉ា សមស្របបំផុតតែបើមានបំណងចង់បានទាដែលផលិតស៊ុតខ្ពស់ក្នុងករណីនេះជម្រើសគួរតែយកពូជកាគីកាំបែល ។ទាប៉េកាំង ជាពូជល្អបំផុតសម្រាប់ផលិតសាច់ តែទាកូនកាត់រវាងពូជនាំចូល និងពូជក្នុងស្រុកសមស្រប សម្រាប់ការផលិតស៊ុត និងសាច់ផង ។

## ២.៣ ទាស្រុក

ជាច្រើនជំនាន់មកហើយ ដែលកសិករនៅកម្ពុជា ចិញ្ចឹមទាពូជក្នុងស្រុក ដោយសារគុណភាពនៃសាច់របស់វាមានខ្លាញ់ទាប ហើយសមស្របសម្រាប់ការចិញ្ចឹមជាលក្ខណៈគ្រួសារ ។ ទាស្រុកសមស្របសម្រាប់អ្នកទើបចាប់ផ្តើមចិញ្ចឹមទាដោយសារវាអាចធន់នឹងអាកាសធាតុមិនល្អ និងរដូវកាលដែលខ្វះចំណី ។ ទាស្រុកប្រសើរណាស់ក្នុងការដើររកចំណីដោយខ្លួនវា ។ តែគួរឱ្យសោកស្តាយដោយសារវាមានជើងខ្លីធ្វើឱ្យដងខ្លួនវាស្ទើរតែអូសដី ដែលធ្វើឱ្យវាមានការលំបាកក្នុងការដើរឆ្ងាយ ។ ជាទូទៅ ទាស្រុកផលិត ៦០-៨០ ស៊ុតក្នុងមួយឆ្នាំតែផលិតកម្មស៊ុតអាចកើនឡើង ដោយកែលំអការគ្រប់គ្រង និងចំណី ។



ទាស្រុក

**២.៣.១ ទាសំពៅ**

មានការនិយមចូលចិត្តចិញ្ចឹមទាសំពៅនៅជនបទនៃប្រទេសកម្ពុជាដោយសារស៊ុតរបស់វាធំ ។ ទាសំពៅមានទំហំខ្លួនមធ្យម និងពូកែដើររកចំណី ។ ទាសំពៅត្រូវបានសំគាល់តាមរយៈបង្កង់សរនៅត្រង់ករ និង រោមរបស់វាលឿងភ្លឺ ចំពុះត្នោត និងជើងលឿង ។ ពួកវាចាប់ផ្តើមផលិតស៊ុតនៅអាយុ ៥-៦ខែ ។

**២.៣.២ ទាអង្កាម**

ទាអង្កាមមានជើងតូច ហើយខ្លី និងករខ្លី មានដងខ្លួនតូច និងមានរោមពណ៌ចាប់ពីលឿងទុំ រហូតដល់ពណ៌ត្នោតដែលមានចំណុចខ្មៅតូចៗ ។ ពូជនេះមានលក្ខណៈសម្បត្តិសមស្របសម្រាប់ផលិតកម្មខ្នាតតូចដោយសារវាធន់នឹងភាពរាំងស្ងួតនឹងជំងឺ រួមបញ្ចូលទាំងពពួកប៉ារ៉ាស៊ីត។ ក្រៅពីនេះពួកវាប៉ិនដើររកចំណីដូចជារុក្ខជាតិទឹកដែលមានបរិមាណទឹកខ្ពស់ ។ ពួកវាអាចស៊ីចំណីដូចជា ចកបាយទា ស្មើនឹងទម្ងន់ខ្លួនវា ។



**ទាអង្គាម**

### ២.៣.៣ ទាកាប៉ា

ទាកាប៉ាខុសគ្នាទាំងស្រុងពីពូជទាក្នុងស្រុកដទៃទៀត ដោយសារវាអាចភ្ញាស់ស៊ុតរបស់វា មានទំហំខ្លួនធំ មានរោមពណ៌ខ្មៅ តែក៏មានពណ៌សសុទ្ធ និងខ្មៅលាយសផងដែរ ។ ទាញីចាប់ផលិតស៊ុត នៅអាយុ ៥-៦ខែ ដែលមានពង១៥-២០គ្រាប់ សម្រាប់ការពងមួយលើកៗ ។ ទាកាប៉ាមានការនិយម ចូលចិត្តណាស់ នៅប្រទេសកម្ពុជាដោយសារវាធន់នឹងជំងឺ និងចំណីមានគុណភាពទាប ។ ទាប្រភេទនេះមាន ការបន្តពូជបានល្អដែលអាត្រាស៊ុតវាអាចមានរហូតដល់ ៨០-៩០% ។ ទាកាប៉ាឈ្មោលអាចមានទំងន់ដល់ទៅ ៤-៥គក្រ ហើយញីវិញ ១-១,៥គក្រ ។ ទាកាប៉ាញី ជាមេទាល្អអាចថែរក្សាកូនវាបានគង់វង្សច្រើន ។ ពូជ ទានេះសមស្របណាស់សម្រាប់កសិករដោយសារវាពូកែរកចំណី និងភ្ញាស់កូនខ្លួនវាបាន ។ពងទាកាប៉ាត្រូវការ ៥ អាទិត្យដើម្បីញ៉ាស់ផ្ទុយពីទាធម្មតាដែលត្រូវការតែរយៈពេល៤អាទិត្យ ។ ទាកាប៉ាឈ្មោលអាចបង្កាត់ពូជជាមួយទាញីផ្សេងទៀតហើយកូនកាត់របស់ពូជទាំងពីរ ជាទូទៅធំលឿននិងផលិតសាច់បានល្អសម្រាប់ទីផ្សារ ។



**ទាកាប៉ា**

## ២.៤ ពូជទានាំចូល

### ២.៤.១ ភាគីកាំបែល

ទាពូជនេះត្រូវបានបង្កើតឡើងដោយអ្នកស្រី កាំបែលនៃប្រទេសអង់គ្លេសដែលអ្នកស្រីបានបង្កាត់ពូជទាអង់គ្លេសជាមួយពូជទាអិនណ្ឌា។ ទាពូជនេះមានពណ៌កាគីអាចមានពណ៌ប្រផេះលឿងស្រាលហើយមានទំហំប្រហាក់ប្រហែលទាស្រុកនៅកម្ពុជាតែវាមានដងខ្លួនទ្រវែង និងជើងវែង។ ទានេះមានជើង និងក្រចកពណ៌ត្នោត ។ ទានេះអាចពង ២៥០-៣០០គ្រាប់ក្នុងមួយឆ្នាំ ឬក៏ច្រើនជាងនេះ ។ ទំងន់ជាមធ្យមរបស់ទានេះ គឺ ១,៥-២គក្រ ។ ពួកវាដើររាងងើបមុនដែលអាចឱ្យវាមានលទ្ធភាពរកចំណីឆ្ងាយបាន ។

### ២.៤.២ ទាប៉េកាំង

ទាពូជនេះមិនមានចិញ្ចឹមខ្នាតតូចជាលក្ខណៈគ្រួសារនៅកម្ពុជាទេ ដោយសារវាត្រូវការចំណីមានគុណភាពពិសេស និងបរិមាណច្រើនដើម្បីលូតលាស់បានឆាប់ ។ ទាប៉េកាំងឃើញមានចិញ្ចឹមជាខ្នាតមធ្យម និងជាលក្ខណៈឧស្សាហកម្ម ។ ទាពូជនេះមានទំងន់ ៣,៥-៤គក្រនៅពេលពេញវ័យ ។ នៅពេលផ្តល់ចំណីគ្រប់គ្រាន់វាមានទំនង់ ២,៥-៣គក្រក្នុងរយៈពេល៣ខែ។ ចំពុះទានេះមានពណ៌ទឹកក្រូចនិងជើងពណ៌

លឿងទុំ ហើយស្បែកពណ៌លឿង ។ ទាប៉េកាំងមិនមែនជាពូជទាពងទេ តែវាអាចពង ១០០-១៥០គ្រាប់ក្នុងមួយឆ្នាំ ។




**ទាប៉េកាំង**

### ២.៤.៣ ទាកូនកាត់

ជាទូទៅ ពូជទាកូនកាត់ល្អប្រសើរតាមរយៈការបង្កាត់ពូជទាផ្សេងគ្នា ។ ពូជកូនកាត់មួយក្នុងចំណោមពូជកូនកាត់ផ្សេងទៀត គឺរវាងកាគីកាំបែលឈ្មោល និងទាក្នុងក្រុមញី ។ ពូជកូនកាត់ដែលទទួលបាន អាចសមស្របទៅតាមលក្ខខណ្ឌក្នុងស្រុក និងពងច្រើន ឬធំធាត់បានលឿនជាងទាស្រុក ។ ទាកូនកាត់នេះអាចពង ១០០-២០០គ្រាប់ក្នុងមួយឆ្នាំ ។

## ២.៥ តំរូវការនៃការចាប់ផ្តើមចិញ្ចឹមទា

នៅពេលកសិករមានផែនការចិញ្ចឹមទា បញ្ហាទីមួយដែលត្រូវមើល គឺចំណីសម្រាប់ទា ។ កសិកររស់នៅក្បែរប្រភពទឹក ដូចជាដងទន្លេ បឹង និងតំបន់ទំនាបលិចទឹក ព្រោះនៅទីនោះមានប្រភពធនធានចំណីច្រើនដូចជា ខ្យង ក្តាម សត្វល្អិតក្នុងទឹក និងរុក្ខជាតិក្នុងទឹក។ ចំណីទីពីរ គឺថ្នាំសម្រាប់ការពារ និងព្យាបាលទា។ ជំងឺសំខាន់ៗសម្រាប់ទាមាន អាសន្នរោគ និងប៉េស្តទាតែនៅពេលបច្ចុប្បន្នមានជំងឺផ្តាសាយបក្សី

ដែលជាបញ្ហាចោទដ៏សំខាន់មួយហើយមិនទាន់មានការទប់ស្កាត់ និងព្យាបានមានប្រសិទ្ធិភាពនៅឡើយ ។ មានបទដ្ឋានមួយចំនួនដើម្បីអនុវត្តក្នុងការចិញ្ចឹមទាឱ្យជោគជ័យៈ

- ✓ ផ្តល់ចំណីដល់ទាឱ្យគ្រប់គ្រាន់ និងមានគុណភាពល្អ
- ✓ ជ្រើសរើសទាដែលមានសុខភាពល្អសម្រាប់ចាប់ផ្តើម
- ✓ ចាក់ថ្នាំបង្ការជំងឺនានា និង
- ✓ ថែទាំទាឱ្យល្អ

ជាទូទៅត្រូវចាប់ផ្តើមដោយសិក្សានិងយល់ឱ្យគ្រប់ផ្នែកលើការចិញ្ចឹមទាជាមុននិងសូមអាចព័ត៌មានដែលផ្តល់នៅក្នុងបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះមុនចាប់ផ្តើមគំរោង ។កសិករដែលមានជំនួយការពីអ្នកផ្សព្វ ផ្សាយត្រូវយល់ពីតំរូវការអាហាររូបត្ថម្ភសម្រាប់ទាប្រភេទនីមួយៗ និងធនធានមានសក្តានុពល សម្រាប់ចំណីទា ។ កូនទាមានតំរូវការចំណីតិចតួច តែត្រូវមានគុណភាពល្អ និងមានប្រតេអូ៊ីនខ្ពស់(២០,២២%ក្នុងម៉ាស់ស្ងួត) ហើយទាត្រូវការចំណីច្រើននៅពេលវាកាន់តែធំតែកំរិតប្រូតេអ៊ីនថយចុះប្រៀបជាមួយកូនទា (១៦-១៨%ក្នុង ម៉ាស់ស្ងួត) ។មេទាពងត្រូវការចំណីមានប្រូតេអ៊ីន ៤-១៥% ក្នុងចំណីរបស់វាតែមានការបន្ថែមកាល់ស្យូម ពីម្សៅឆ្អឹង ឬសំបកស៊ុត ។ ប្រសិនបើទាពងមានផ្តល់កូនខ្យងនិងក្តាមពួកវាទទួលរ៉ែគ្រប់គ្រាន់តាមតំរូវការរបស់វាហើយ ។

ទាត្រូវការប្រូតេអ៊ីន ថាមពល រ៉ែ ជីវជាតិ និងទឹក ។ ប្រូតេអ៊ីនដែលនិយមប្រើជាទូទៅមានតម្លៃថ្លៃហើយមិនងាយរកនៅតាមជនបទទៀតផងតែកសិករអាចផលិតនិងរកចំណីផ្សេងជំនួសបាននៅតាមភូមិរបស់ពួកគាត់ដូចជា ចកបាយទា ជន្លេន ត្រកួន ខ្យង ក្តាម និងកូនត្រី និងកំពិសតូចៗ ។ល។នៅរដូវវស្សាពពួកប្រូតេអ៊ីនប្រភេទនេះ មានលក្ខណៈងាយស្រួលនឹងរក ឬក៏ទាអាចដើររកស៊ីខ្លួនវាបាន ។

### ២.៥.១ តំរូវការចំណី

ភាពជោគជ័យនៃការចិញ្ចឹមទា អាស្រ័យយ៉ាងខ្លាំងលើទីតាំងដែលអាចរកប្រភពធនធានចំណីធម្មជាតិពេញមួយឆ្នាំ ។ ប្រសិនបើចិញ្ចឹមទា នៅទីតាំងនោះដោយមានការគ្រប់គ្រងត្រឹមត្រូវអ្នកចិញ្ចឹមនឹងបានចំណេញច្រើន។ កសិករត្រូវមានផែនការថា តើគេត្រូវផ្តល់អ្វីឱ្យទាស៊ីមុននឹងចាប់ផ្តើមគំរោងចិញ្ចឹមទា ។ទីតាំងសមស្របដែលលើកឡើងខាងលើជាទូទៅ មិនសូវមានគ្រប់ទីកន្លែងនៅទូទាំងប្រទេសកម្ពុជាទេដូច្នេះ កសិករគួរចាប់ផ្តើមចិញ្ចឹមកូនទានៅដើមរដូវវស្សា ដែលធ្វើឱ្យកសិករអាចមានលទ្ធភាពទទួលផលពីធនធាន ធម្មជាតិនៅក្នុងទឹកក្បែរផ្ទះ ដូចជាប្រឡាយ ស្រះ បឹង ។ល។

**សំណួរមួយចំនួនដែលកសិករត្រូវសួរខ្លួនឯង:**

- ✓ តើមានប្រភពធនធានចំណីពេញមួយឆ្នាំដែរឬទេ?
- ✓ តើប្រភពធនធានចំណីអ្វីខ្លះដែលទាអាចស៊ីបាន? តើមួយណាជាចំណី ប្រូតេអ៊ីន ថាមពល ជីវជាតិ និងរ៉ែ?
- ✓ តើមានចំណីណាខ្លះដែលអាចផលិតនៅក្នុងកសិដ្ឋាន?
- ✓ តើចំណីណាដែលត្រូវទិញពីផ្សារ?
- ✓ តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីកាត់បន្ថយអាត្រាងាប់របស់ទា?

ចំណីធម្មជាតិដែលទាអាចស៊ីមានដូចខាងក្រោម

| **ចំណី** | **ប្រូតេអ៊ីន** | **ថាមពល** | **រ៉ែ** | **ជីវជាតិ** |
|---|---|---|---|---|
| ខ្យង | **** | | ** | |
| ជន្លេន | ***** | | * | |
| សត្វល្អិត | **** | | * | |
| កូនក្តាម | ** | | * | |
| កូនត្រី | ***** | | * | |
| ចកបាយទា | **** | | * | * |
| ត្រកួន | *** | | * | * |
| ស្មៅខ្ចី | ** | | * | * |
| កន្ទក់ | * | *** | * | * |
| ចុងអង្ករ | * | **** | | * |
| ស្រូវ | * | ** | * | * |
| មើមដំឡូងឈើ | | **** | * | |

**ចំណាំ:**

- ✓ ផ្កាយប្រាំមានន័យថាមានច្រើន ហើយផ្កាយមួយមានតិច
- ✓ ដើម្បីទទួលបានព័តិបន្ថែមលើការផលិតចំណីមួយចំនួនដូចបានលើកឡើងក្នុងតារាងខាងលើ សូមអាន បទដ្ឋានអនុវត្តបច្ចេកវិទ្យាស្តីពី ”ការគ្រប់គ្រងមេ **និងកូនមាន់នៅជនបទ”**

ចំណីធម្មជាតិមានគុណភាពល្អប្រសើរសម្រាប់ទា ប្រសិនអាចឱ្យទាជ្រើសរើសចំណីទាំងនោះដោយខ្លួនវា ព្រោះ ដឹងថាតើចំណីប្រភេទណាដែលវាត្រូវសម្រាប់ការលូតលាស់ និងផលិតកម្មរបស់វា ជាជាងការដាក់វាក្នុងទ្រុងដោយឱ្យស៊ីចំណីផ្សំ ។ ប៉ុន្តែដោយសារជំងឺជាបញ្ហាធំ ដូចជា ផ្តាសាយបក្សី អាសន្នរោគ និងប៉េស្តទា ដូចនេះទាត្រូវដាក់ទ្រុង ឬបង្ខាំង ហើយឱ្យចំណីដែលផ្សំឱ្យវាស៊ី ដោយប្រើធនធានចំណីដែលមាននៅមូលដ្ឋាន ឬក៏ផលិតនៅកសិដ្ឋានរបស់ខ្លួនដូចជា ត្រកួន ជន្លេន ។ល។

### ២.៥.២ ទ្រុងទា

សំណង់ទ្រុងទាត្រូវសាមញ្ញជាពិសេសសម្រាប់កសិករចិញ្ចឹមជាលក្ខណៈគ្រួសារតែត្រូវមានខ្យល់អាកាសចេញចូលគ្រប់គ្រាន់ និងត្រូវឱ្យស្អាត ។ កសិករត្រូវអនុវត្តតាមការណែនាំដូចខាងក្រោមៈ

- ✓ រក្សាទ្រុងទាឱ្យស្អាត
- ✓ ក្រាលកំរាលទ្រុងទា ដោយប្រើអង្កាម អាចម៍រណារ ឬចំបើងកាត់តូចៗ

**ចំណាំៈ**

- ✓ ប្តូរកំរាលពីរដងក្នុងមួយសប្តាហ៍
- ✓ ក្រោយពីប្រមូលកំរាលនោះជាជីធម្មជាតិដ៏ល្អសម្រាប់ដំណាំដោយសារវាមានទឹក និងលាមកលាយគ្នា
- ✓ ទាពងផ្ទាល់ដី ប្រសិនបើមានកំរាល អាចកាត់បន្ថយការបែកពង ហើយធ្វើឱ្យពងស្អាត

កសិករដែលមើលទាហ្វូងលើសពី ១០០ក្បាល នៅរដូវច្រូតកាត់ពួកគេតែងតែឱ្យហ្វូងទាឈប់សម្រាកនៅវាលស្រែដែលគេអាចទៅដល់នៅពេលរសៀល ហើយទាហ្វូងទាំងនោះដេកនៅទីវាលល្ហល្ហេវ ។ ជួនកាលកសិករប្រើប្រួលសម្រាប់បិទបាំងទាទាំងនោះ ហើយក៏ជួនកាលគ្មានអ្វីបិទបាំងទាំងអស់តែម្ចាស់នៅសំរាកក្បែរនោះ។វិធីនេះកសិករដែលចិញ្ចឹមទាលើសពី ១០០ក្បាល តែងតែអនុវត្តហើយទាហ្វូងនេះសម្រាប់យកសាច់។ កសិករខ្លះបណ្តើរទាហ្វូងរបស់គេចំងាយឆ្ងាយដើម្បីឱ្យទារកអាហារ ហើយពួកគេក៏ចំណាយពេលច្រើនអាទិត្យជាមួយហ្វូងទា ។




ធ្វើដំបូលទ្រុងទាកំពស់ ១,២-១,៥មពីដី និងបាំងប្រួលជុំវិញទុកឱ្យសល់ទីវាលសម្រាប់ពន្លឺព្រះអាទិត្យ

**២.៥.៣ ជ្រើសរើសទាពង**

ប្រសិនបើកសិករមានបំណងចិញ្ចឹមទាពង ត្រូវទិញមេទាក្រមុំដែលមានអាយុ១ឆ្នាំព្រោះអាយុនេះទាចាប់ពងល្អទោះបីជាវាមានអាយុរហូតដល់៣ឆ្នាំក៏ដោយ ក៏អាចនៅបន្តពងបានល្អ ។ កសិករគួរយល់ដឹង លក្ខណៈមេទាដែលពងល្អ ដែលក្នុងនោះមានៈ

- ✓ រោមមានពណ៌ស្រអាប់ ហើយមានស្លាបខ្ចះបាក់
- ✓ គ្មានរោមលើក្បាលខាងក្រោយដោយសារឈ្មោលចឹកទាញនៅពេលឡើងពាក់ និង
- ✓ មេទាដែលពងល្អមានដងខ្លួនទ្រវែង ។

**ចំណាំ**

- ✓ មេទាដែលមានអាយុប្រហាក់ប្រហែលគ្នា មិនសូវពងនោះ មានរោមភ្លឺស្អាត
- ✓ ទាឈ្មោលមួយអាចពាក់មេទាពី ៧-១០ ក្បាល
- ✓ ប្រសិនត្រូវទិញមេទាកូនកាត់ ត្រូវសាកសួរឱ្យច្បាស់ថាឈ្មោលដែលបានពាក់នោះ ជាពូជនាំចូលសុទ្ធល្អ ដើម្បីធានាថា កូនវាមានឈាមជាទាផលិតស៊ុត

### ២.៥.៤ ការទិញកូនទា

កូនទាមានលក់ជាទូទៅនៅទីផ្សារនៅទីក្រុងភ្នំពេញ និងទីប្រជុំជន។ កូនទាមួយក្បាលមានតម្លៃ ៥០០-៦៥០រៀល ។ កសិករត្រូវជ្រើសរើសកូនទាដែលមានភ្នែកភ្លឺថ្លា និងរោមស្ងួតល្អ ។ ជួនកាលកូនញាស់មកខ្សោយ ហើយងាប់នៅក្នុងរយៈពេលខ្លី។ មានកូនទាខ្លះញាស់មកមិនគ្រប់លក្ខណៈ និងមិនអាចមើលឃើញដោយងាយស្រួល ក៏អាចងាប់ក្នុងរយៈពេលខ្លីដែរ ។ កសិករត្រូវមើលស្ថានភាព និងលក្ខណៈកូនទាឱ្យបានល្អិតល្អន់ប្រសិនបើមើលទៅសង្ស័យថា វាមិនមានសុខភាពល្អទេកុំទិញឱ្យសោះ ។ កូនទាអាយុមួយថ្ងៃទោះបីមានសុខភាពល្អយ៉ាងណាក៏ដោយ ក៏តំរូវឱ្យចំណាយពេលវេលាច្រើនសម្រាប់ការថែទាំវាឱ្យបានគ្រប់គ្រាន់ ។ ជួនកានកសិករក៏អាចទិញកូនទាដែលមានអាយុ ២-៣ខែផងដែរ ។ ទាដែលមានអាយុនេះអាច សមស្របសម្រាប់កសិករដែលមានបទពិសោធន៍តិចតួចក្នុងការចិញ្ចឹមទា ប៉ុន្តែកូនទានៅអាយុនេះមានតម្លៃថ្លៃ តែសារៈប្រយោជន៍គឺទានៅអាយុនេះមិនសូវត្រូវការថែទាំយ៉ាងមមាញឹកនោះទេបើប្រៀបធៀបជាមួយកូនទា ។ ដូច្នេះកសិករត្រូវជ្រើសរើសទាទាំងនោះដោយមានៈ

- ✓ ភ្នែកភ្លឺ និងមូល
- ✓ រោមរាបជាប់ស្បែក និងភ្លឺថ្លា
- ✓ ទ្រូងទូលាយ
- ✓ មានដងខ្លួនងើបត្រង់ និង
- ✓ កររឹងស្អួច

**ចំណាំ**

- ✓ ទាមានដងខ្លួនខ្លី ធាត់ អាចជាពូជដែលផលិតស៊ុតទាប

### ២.៥.៥ ផលិតកូនទា

ទាជាធម្មតាមិនក្រាបពងវាទេលើកលែងតែទាកាប៉ា ។ ក្នុងករណីនេះពងរបស់ទាទូទៅត្រូវឱ្យមានក្រាបហើយក៏អាចឱ្យមេមាន់បណ្តើរនៅអាទិត្យទីមួយ និងទីពីរក្រោយពេលញាស់ ។ ប្រសិនបើកសិករមានធនធានល្មមអាចធ្វើកើតកូនទាត្រូវយកចេញពីមេមាន់ ហើយកូនទាទាំងនោះត្រូវថែទាំដោយម្ចាស់ ។

**ចំណាំ**

- ✓ ពងទាជាទូទៅធំជាងពងមាន់ ដូច្នេះហើយកសិករអាចដាក់ពងទាឱ្យមេមាន់ក្រាបត្រឹមតែ ១៥ គ្រាប់ប៉ុណ្ណោះ។
- ✓ ចំនួនពងទាដែលដាក់ឱ្យមាន់ក្រាបក៏ត្រូវមើលទៅលើទំហំខ្លួនរបស់មេមាន់ដែរ
- ✓ រក្សាកន្លែងដែលមេមាន់ក្រាបឱ្យស្អាតល្អ និងផ្តល់សំបុកពងដែលមានចំបើងក្រាលត្រឹមត្រូវ
- ✓ ទីកន្លែងក្រាបផ្តល់លទ្ធភាពឱ្យមេមាន់ក្រាបពងចុះរកចំណី និងទឹក ។

ប្រសិនបើមេមាន់មិនត្រឡប់ចូលក្រាបពងវិញទេអាចដោយសារមានស្រមើរ (សត្វល្អិតតូចជញ្ជក់ឈាមមេមាន់)នៅក្នុងសំបុកក្រាប ។ ក្នុងករណីនេះយកពងចេញទាំងអស់ទុកកន្លែងដែលមានកំដៅរួចយកចំបើងដុតចោលហើយយកប្រេងកាត ឬទឹកក្តៅស្រោចលើបង្គី ឬល្អីសំបុកពង ។ ក្រោយពីអនុវត្តការងារនេះរួចយកចំបើងថ្មីមកដាក់សារជាថ្មីទើបយកពងមកដាក់ឡើងវិញ។ កុំភ្លេចដាក់ថ្នាំជក់ (ថ្នាំខ្លាំងនៅក្នុងសំបុកពងដើម្បីជៀសវាងស្រមើរសារជាថ្មី ) ។

រយៈពេលនៃការក្រាបពងអាស្រ័យលើពូជទា ដែលរយៈពេលក្រាបរបស់វាខុសៗគ្នាៈ

- ✓ ពងទានៃពូជទាទូទៅ ត្រូវការរយៈពេល ២៦-២៨ ថ្ងៃ សម្រាប់ញាស់
- ✓ ពងទាកាប៉ាត្រូវការរយៈពេល ៣៥ថ្ងៃ ដើម្បីញាស់ និង
- ✓ កូនទាពូជកូនកាត់ត្រូវការរយៈពេល ៣០ ថ្ងៃ ដើម្បីញាស់ ។

**ចំណាំ**

- ✓ ជ្រើសរើសពងទាស្អាតមានទំហំធំ និងទំរង់មូលទ្រវែងដែលមានសំបករលោង
- ✓ ប្រសិនបើពងប្រលាក់លាមក ឬក្រខ្វក់ត្រូវជូតសំអាតជាមួយទឹកក្តៅល្មមហើយដាក់សំដិលឱ្យស្ងួតភ្លាម
- ✓ កូនទាទាំងមិនញាស់ពេលជាមួយគ្នានោះទេ ។ ចំពោះកូនទាដែលញាស់មុនគេបង្គស់អាចយកចេញទៅដាក់ក្នុងកញ្ជេរក្រាលអង្កាម ឬចំបើងហើយគ្របបាវពីលើរង់ចាំរហូតដល់កូនទាទាំងអស់ញាស់ ។ធ្វើតាមវិធីនេះជៀសវាងមេមាន់ជាន់កូនទាឬមួយចាកចេញពីល្អីក្រាបពង ។

## ២.៦ ការចិញ្ចឹមកូនទា

ពេលវេលាល្អសម្រាប់ចិញ្ចឹមកូន គឺនៅដើមរដូវវស្សា ។ កូនទាត្រូវការ ការថែទាំបានល្អ ដូចជាកំដៅត្រឹមត្រូវការផ្តល់ចំណីនិងអនាម័យ។ អនុវត្តការថែទាំ និងគ្រប់គ្រងបានល្អរួមបញ្ចូលទាំងការផ្តល់ចំណីធ្វើឱ្យអាត្រានៃការរស់រានរបស់កូនទាមានកំរិតខ្ពស់ ។

### ២.៦.១ កន្លែងដាក់កូនទា

កូនទាពីញាស់រហូតដល់អាយុ ១៥ ថ្ងៃត្រូវរក្សាទុកក្នុងកញ្ជេរ ឬទ្រុងស្អាត។ វិធានការដូចខាងក្រោមត្រូវអនុវត្តៈ

- ✓ នៅក្នុងកញ្ជេរ ឬទ្រុងត្រូវមានកំរាលអង្កាម អាចម៍រណា ឬចំបើង កំពស់ ២-៣សម
- ✓ កំរាលត្រូវផ្លាស់ប្តូរជានិច្ចដើម្បីឱ្យកូនស្ងួតល្អ
- ✓ អាចបន្ថែមអង្កាម អាចម៍រណា ឬចំបើង រៀងរាល់ថ្ងៃពីលើកំរាលចាស់ និង
- ✓ កសិករមិនគួរដាក់កូនទាច្រើនពេកទេនៅក្នុងកញ្ជេរមួយនោះ ដើម្បីឱ្យពួកវាមានលទ្ធភាពធ្វើចលនា ប៉ុន្តែបើទូលាយពេកធ្វើឱ្យកូនទាមិនមានកំដៅគ្រប់គ្រាន់ធ្វើឱ្យពួកវាស្មោរនិងអាចងាប់ ។




**ទ្រុងដែលមានកំរាលអង្កាមសម្រាប់កូនទាអាយុ ១-១៥ថ្ងៃ**

**ចំណាំ**

- ✓ អគ្គីសនីត្រូវបានប្រើប្រាស់សម្រាប់ការចិញ្ចឹមទាជាលក្ខណៈឧស្សាហកម្ម ហើយអ្នកដែលមានបណ្ដាញអគ្គីសនី ក៏អាចប្រើប្រាស់បានដែរ ដើម្បីផ្ដល់កំដៅដល់កូនទាពី ១-៧ ថ្ងៃ
- ✓ នៅតំបន់ជនបទ និងសម្រាប់កសិករចិញ្ចឹមទាខ្នាតតូច អាចប្រើធ្យូងសម្រាប់ផ្ដល់កំដៅបាន
- ✓ ឆ្នាំងដី ឬក្អមដែលមានចោះរន្ធតូចៗនៅសងខាង និងគំរបពីលើ អាចប្រើសម្រាប់ដាក់ធ្យូងផ្ដល់កំដៅនេះដល់កូនទា
- ✓ ដើម្បីឱ្យកំដៅនៅក្នុងទ្រុងល្អ ត្រូវមានបិទជញ្ជាំងជុំវិញ ដោយប្រើស្លឹកត្នោត ឬបាវចាស់ៗ កុំឱ្យខ្យល់បកចូលខ្លាំង ។

កសិករម្ចាស់ទាត្រូវពិនិត្យមើលសញ្ញាណសម្រាប់វិធានការណ៍ បាច់នានាធ្វើឱ្យកូនទាមានសុខភាពល្អ

- ✓ នៅពេលមានកំដៅខ្លាំងនៅក្នុងទ្រុង ឬកញ្ជោរកូនទាងើបក្បាលឡើងលើ និងដួនកាលស្រែក ប្រសិនពិនិត្យឃើញមានលក្ខណៈបែបនេះ កសិករត្រូវយកអ្វីដែលបាំងជុំវិញ និងខាងលើចេញដើម្បីឱ្យមានខ្យល់ចេញចូល ។
- ✓ ចាំបាច់ត្រូវពិនិត្យមើលកំរាលប្រសិនបើក្រខ្វក់ដោយទឹកលាមកនិងចំណី ក៏អាចបង្កឱ្យកំដៅខុស ធម្មតានៅក្នុងទ្រុងទា និង
- ✓ នៅពេលដែលត្រជាក់ខុសធម្មតា កូនទាប្រមូលផ្ដុំ ដើម្បីឱ្យមានកំដៅ ។ នៅពេលនេះ កសិករត្រូវផ្ដល់កំដៅឱ្យពួកវា ។



**ផ្ដល់កំដៅនៅពេលកូនទាប្រមូលផ្ដុំគ្នា**

**ចំណាំៈ**

- ✓ កូនទាត្រូវរក្សានៅក្នុងសីតុណ្ហភាព ២៦,៥-២៩,៥ អង្សារសេ សម្រាប់កូនទាអាយុ ១ថ្ងៃ ទៅ ១០-១៥ថ្ងៃ ។

### ២.៦.២ ការផ្ដល់ចំណី

កូនទាចាប់ផ្ដើមស៊ីចំណីក្រោយពេលញាស់ហើយនឹងធំធាត់យ៉ាងឆាប់រហ័ស ហេតុដូច្នេះហើយត្រូវផ្ដល់ចំណីដល់វាបានត្រឹមត្រូវដើម្បីស្រូបយកសក្ដានុពលនៃការលូតលាស់របស់វា និងមានសុខភាពល្អ (តារាងទី ១) ។

- ✓ ផ្ដល់ចំណីដល់កូនទា ៤-៥ដង ក្នុងមួយថ្ងៃ
- ✓ លាយចំណីផ្សំឱ្យច្រើនមុន
- ✓ កូនទាចូលចិត្តស៊ីចុងអង្ករ និងកន្ទក់ឆៅ ឬចំអិន ដែលផ្ដល់សំខាន់ប្រភពថាមពល
- ✓ បន្ថែមប្រូតេអ៊ីនដូចជាត្រីតូចៗ ឬជន្លេនកាត់តូចៗ ធ្វើឱ្យកូនទាឆាប់ធំធាត់លឿន
- ✓ បន្ថែមកូនក្ដាម ខ្យង ជាប្រភពរ៉ែ និង
- ✓ ផ្ដល់បន្លែបៃតងដូចជាត្រកួន ឬចកបាយទា ជាប្រភពវីតាមីន ។

**ចំណាំ**

- ✓ កូនទាចូលចិត្តចំណីសើម ដូចជាចកបាយទា ពួកវាអាចស៊ីស្មើនឹងទំងន់វា
- ✓ កុំផ្តល់ចំណីដល់កូនទានៅក្នុងកញ្ជេរ ឬទ្រុង។ ឱ្យវាស៊ីនៅលើកំរាលមួយអាច ជាប្លាស្ទិក កន្ទេលចាស់ ឬក្រដាស ឬឱ្យស៊ីនៅក្នុងកញ្ជេរផ្សេង និង
- ✓ ក្រោយពេលឱ្យចំណីរួចត្រូវដាក់កូនទាទៅក្នុងចានទាបមួយដែលមានទឹក ១-១,៥ សម ។ ក្រោយពីឱ្យវាលេងទឹកសំអាតខ្លួនរួចហើយ ទើបដាក់ពួកវាទៅលើកំរាលស្ងួត ឬលើកំរាលអង្កាមដើម្បីសំងួតពួកវាមុននឹងដាក់វាចូលទៅក្នុងកញ្ជេរ ឬទ្រុងដើមវិញ ។

តារាងទី១ ចំណីកូនទា ទាជំទង់ (អាយុលើសពី ៦អាទិត្យ) និងទាពង

| **វត្ថុធាតុដើម** | **កូនទា (គក្រ)** | **កូនទា (គក្រ)** | **ទាជំទង់ (គក្រ)** | **ទាពង (គក្រ)** | **ទាពង (គក្រ)** |
|---|---|---|---|---|---|
| ចុងអង្ករ | ៣៤ | ៣៦ | ៣៤ | ៣៥ | ៣៤ |
| កន្ទក់ | ២២ | ២០ | ២០ | ២០ | ១៧ |
| ម្សៅមើលដំឡូងឈើ | | ១៥ | ១៦ | | ១២ |
| ពោត | ៤ | | | ១៥ | ១៣ |
| ម្សៅត្រី | ១៣ | ៥ | ៨ | | |
| កូនត្រីស្រស់ | | | | | ៥ |
| សណ្តែកសៀង | | | | ៩ | ១ |
| ជន្លេន | | ៦ | | | |
| ចកបាយទា | | ៧ | | | |
| ត្រកួន | ១៣ | ១២ | ១៣ | | ១៣ |
| ម្សៅស្លឹកដំឡូងឈើ | ១៣ | | ៩ | ១៥ | |
| អំបិល | ០,៥ | ១ | ១ | ១ | ១ |
| ម្សៅសំបកខ្យង | | | | ៥ | ៤ |
| | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| **%ប្រូតេអ៊ីន** | **២០,៦** | **២០,៦** | **១៦,៨** | **១៥,៦** | **១៥,៧** |

### ២.៦.៣ ការលេងទឹក

ទាជាទូទៅចូលចិត្តទឹកដើម្បីហែល ក៏ដូចជាស្វែងរកចំណីនៅក្នុងទឹក ហេតុដូចនេះហើយកសិករត្រូវៈ

- ✓ ឱ្យកូនទាលេងទឹកនៅក្នុងចានដែលមានទឹក ៣-៥ សម ក្នុងរយៈ៤-៥នាទី នៅពេលថ្ងៃត្រង់
- ✓ ត្រូវឱ្យកូនទាសំដិលខ្លួនឱ្យស្ងួត មុនដាក់ចូលទៅក្នុងទ្រុង ឬកញ្ឆេរវិញ
- ✓ នៅរដូវវស្សា កូនទាក៏អាចឱ្យហែលទឹកនៅក្នុងស្រះតូចៗ និងប្រឡាយនៅក្បែរផ្ទះ
- ✓ កសិករត្រូវប្រាកដថាមានថ្ងៃគ្រប់គ្រាន់ ដើម្បីឱ្យកូនទាសំដិលខ្លួន ហេុតនេះហើយបានជាសំណូមពរកសិករឱ្យកូនទាលេងទឹកនៅពេលថ្ងៃត្រង់ ។

### ២.៦.៤ គ្រប់គ្រងកូនទាអាយុ ២-៤សប្តាហ៍

នៅពេលដែលកូនទាមានអាយុ ២អាទិត្យ ពេលវេលានៃការថែទាំថយចុះ មានសកម្មភាព មួយចំនួន ដែលត្រូវធ្វើរហូតដល់កូនទាមានអាយុ ៤អាទិត្យៈ

- ✓ ដាក់កំរាលដូចជាអង្កាម អាចម៍រណា និងចំបើងតែផ្នែកមួយនៃទ្រុងទា ព្រោះនៅអាយុនេះកូនទាត្រូវខ្យល់អាកាសចេញចូលច្រើន និងពន្លឺថ្ងៃ
- ✓ នៅពេលថ្ងៃកូនទាដើររកចំណីដូចជា សត្វល្អិត និងរុក្ខជាតិនៅក្បែរផ្ទះ ហើយទីកន្លែងនោះអាចជាវាលស្រែ និងថ្លុកដែលសំបូរចំណីធម្មជាតិដូចជាសត្វល្អិត កូនក្តាម ខ្យង និងរុក្ខជាតិក្នុងទឹក
- ✓ ទោះបីដើររកចំណីដោយខ្លួនវាក៏ដោយ ផ្តល់ចំណីអាហារបន្ថែមដល់វាដូចមាននៅក្នុងតារាងទី១ និងទឹកផឹកពីរដងក្នុងមួយថ្ងៃ ធ្វើឱ្យកូនទាមានការលូតលាស់ឆាប់ និង
- ✓ ប្រសិនកសិករអាចមានលទ្ធភាពរកស្នូកចំណីធ្វើពីជ័រ ពួកគាត់យកមកប្រើប្រាស់សម្រាប់ផ្តល់ចំណីដល់ទា ។ ទន្ទឹមនេះកសិករក៏អាចធ្វើស្នូកចំណីពីបំពង់ឫស្សី ឬដបទឹកបរិសុទ្ធ។



**ស្នូកទឹក និងចំណីជ័រ**



**ស្នូកទឹក និងចំណីធ្វើពីបំពង់ឫស្សី**

**ចំណាំ**

- ✓ បញ្ចូលកូនទាក្នុងទ្រុងមានដំបូលនៅពេលភ្លៀង
- ✓ នៅពេលថ្ងៃត្រង់កូនទាត្រូវបញ្ចូលក្នុងម្លប់ក្រោមដើមឈើពីពន្លឺថ្ងៃនៅពេលមានកំដៅក្តៅខ្លាំង
- ✓ ក្រោយពេលនេះ កូនទាអាចបន្តឱ្យរកចំណី តែត្រូវបញ្ចូលទ្រុងមុនងងឹត និង
- ✓ ផ្តល់ចំណីកូនទានៅពេលល្ងាច នឹងធ្វើឱ្យកូនទាត្រឡប់មកទីកន្លែងដើមយ៉ាងងាយស្រួល ។

នៅពេលកូនទាមានអាយុ ៤អាទិត្យ តំរូវការលក្ខខណ្ឌដូចមានចែងខាងក្រោមៈ

- ✓ ទីកន្លែងសម្រាប់ទាមួយក្បាល គឺ 0,0១ម២ ។ ប្រសិនបើកសិករមានដីតូចយ៉ាងហោចណាស់ ត្រូវផ្តល់ 0,00៥ម២ សម្រាប់ទាក្នុងមួយក្បាល ហើយទ្រុងត្រូវមានខ្យល់ចេញចូលល្អ និងស្អាត
- ✓ នៅពេលព្រឹក ផ្តល់ដល់កូនទានូវចំណីដែលបានផ្សំ និងទឹក ។ ប្រើប្រាស់ស្នូតស្អាតសម្រាប់ដាក់ទឹក និងចំណី ។
- ✓ ផ្តល់ចំណីដល់កូនទានៅក្រៅទ្រុងរបស់វា តែនៅកន្លែងដែលធ្លាប់ឱ្យស៊ីជាប្រចាំ និង
- ✓ ទាពេញវ័យចូលចិត្តទឹកភ្លៀង តែកូនទាមិនឱ្យត្រូវទឹកភ្លៀងជាពិសេសនៅពេលភ្លៀងខ្យល់ខ្លាំង ។

**ចំណាំ**

- ✓ នៅពេលដែលទាមានអាយុ ៣-៤ខែ ពួកវាអាចធន់នឹងអាកាសធាតុប្រែប្រួលខ្លាំង ។

## ២.៧ គ្រប់គ្រងទាពេញវ័យ

### ២.៧.១ ចិញ្ចឹមទានៅក្នុងស្រែ

ដោយសារការផ្ទុះឡើងនៃជំងឺផ្តាសាយបក្សី ទាគួរត្រូវបានចិញ្ចឹមនៅកន្លែងមួយមានការបិទបាំងល្អ ក្រោមការគ្រប់គ្រងផ្ទាល់ពីម្ចាស់ ។ ក្នុងករណីនេះកសិករ ត្រូវការថវិកាបន្ថែមសម្រាប់សាងសង់ទីធ្លាចិញ្ចឹមទាកំលាំងពលកម្ម និងចំណី ។ បើមិនធ្វើទ្រុងទេទាអាចគៀង ឱ្យស៊ីនៅក្នុងស្រែ ហើយការពារមិនឱ្យមានសត្វស្លាបផ្សេងទៀតមកក្បែរ ហើយដោយសារវានៅក្បែរផ្ទះ ក្មេងៗអាចទទួលខុសត្រូវលើការងារនេះ ឬដាក់ឱ្យមានទីងមោងក្នុងស្រែនោះ ។ ដើម្បីអនុវត្តវិធីនេះកសិករអាចប្រើសំណាញ់ជ័រសម្រាប់បិទបាំងស្រែក្បែរផ្ទះនោះ

- ✓ កសិករមិនត្រូវឱ្យទាចុះស្រែនៅពេលទើបសាបទើបស្ទូងរួច និងនៅពេលស្រូវចាប់ផលិតគ្រាប់
- ✓ ចំណីដែលផ្តល់ឱ្យទា ត្រូវដាក់នៅក្នុងទ្រុងបិទជិត និងយកចេញនៅពេលវាឈប់ស៊ី ។

**ចំណាំ**

- ✓ កសិករខ្លះមិនឱ្យទាចុះស៊ីក្នុងស្រែទាល់តែសោះដោយយល់ថា ទាអាចធ្វើឱ្យដីស្រែហាប់នៅពេលកំពុង តែធ្វើស្រែ
- ✓ មានផលប្រយោជន៍យ៉ាងច្រើនដោយឱ្យទាចុះស៊ីក្នុងស្រែ ពីព្រោះអាចស៊ីសត្វល្អិតបំផ្លាញស្រូវក្តាមខ្យង ហើយក៏ឱ្យមិនសូវមានស្មៅចង្រៃក្នុងស្រែផងដែរ

- ✓ ទាចុះអាចម៍ក្នុងស្រែដែលផ្តល់ជាប្រភពអាស្សូត និងរ៉ែយ៉ាងល្អសម្រាប់ស្រូវ ។

**២.៧.២ គ្រប់គ្រងទាចាស់ និងទាថ្មី**

ដើម្បីធានាក្នុងការផ្តល់ស៊ុតជាបន្តឱ្យម៉ូយ កសិករត្រូវចាប់ចិញ្ចឹមទាថ្មី នៅពេលដែលទាពង មានអាយុ ២-៣ឆ្នាំ ។ នៅអាយុ ៣,៥ខែ កូនទាហ្វូងថ្មីអាចបញ្ចូលក្នុងហ្វូងទាចាស់ ដើម្បីឱ្យទាចាស់ជួយបង្ហាត់បង្ហាញដល់ទាថ្មី ។ ប្រសិនបើគ្មានទាចាស់នោះទេ ជាពិសេសទាញីជំទង់ដែលទើបទិញចូលត្រូវក្រុងក្នុងទ្រុងមួយអាទិត្យ ដើម្បីឱ្យវាស្គាល់បរិស្ថានជុំវិញដែលត្រូវរស់នៅ ។

- ✓ ទាត្រូវបញ្ចេញទៅក្នុងស្រែពីរដងក្នុងមួយថ្ងៃ នៅពេលព្រឹក និងល្ងាច ។ នៅពេលនោះពួកវាអាចដើររកចំណីនៅទីនោះ
- ✓ ចំណីត្រូវផ្តល់ឱ្យទានៅខាងក្នុង ជៀសវាងបក្សីផ្សេងទៀតចូលមក ។ ចំណីត្រូវឱ្យទៀងពេលដើម្បី លើកទឹកចិត្តត្រឡប់ចូលទ្រុងវិញ
- ✓ ដាក់ទាចូលទ្រុងពេលងងឹត ប៉ុន្តែប្រសិនបង្ខំទាឱ្យចូលទ្រុងថ្ងៃពេកធ្វើឱ្យខុសប្រក្រតីដែលនាំឱ្យទាមិនចូលទ្រុងតែម្តងក៏មានដែរ ។

**ចំណាំ**

- ✓ មិនត្រូវផ្តល់ទឹកដល់ទាភ្លាមនៅពេលវាទើបដើរឆ្ងាយ តែត្រូវផ្តល់ឱ្យវានៅក្នុងទ្រុងពេលយប់ ។

**២.៧.៣ ការគ្រប់គ្រងទាពង**

មានលក្ខខណ្ឌមួយចំនួនដែលត្រូវអនុវត្ត ចំពោះកសិករដែលចិញ្ចឹមទាពង ។ ការអនុវត្តន៍ត្រឹមត្រូវធ្វើឱ្យទទួលផលច្រើន ដូចជាការផលិតស៊ុត និងសុខភាពរបស់ទាៈ

- ✓ លែងទាពងនៅម៉ោង ៧និង៣០នាទីព្រឹក ដោយសារមុនពេលនេះ ទាបានពងរួចរាល់ស្ទើរតែទាំងអស់ ។ ប៉ុន្តែប្រសិនបើទុកវាក្នុងទ្រុងយូរពេក ធ្វើឱ្យទាកញ្ជ្រោល
- ✓ ទាឆាប់ទទួលអ្វីៗដែលផ្លាស់ប្តូរនៅក្នុងជីវិតរបស់វា ដូច្នេះកសិករត្រូវអនុវត្តការងារទៀងទាត់ និងជាប្រចាំ ។ ទានឹងមិនពងត្រឹមត្រូវ ប្រសិនធ្វើឱ្យវាមិនសប្បាយចិត្ត ដោយសារការផ្លាស់ប្តូរពេលវេលាក្នុងការលែងវាចេញក្រៅទ្រុង ឬក៏បញ្ចូលក្នុងទ្រុងវិញ ។
- ✓ ការធ្វើឱ្យទាផ្អើលដោយសារឆ្កែ ឆ្មា និងអ្វីចំឡែកមកក្បែរទ្រុងវាធ្វើឱ្យទាផ្អាកពងហើយការអាក់ពងនេះអាចមានរយៈពេលវែងដល់២ខែ ។




**ទុកទាក្នុងទ្រុងរហូតដល់ម៉ោង ៧០:៣០នាទី ដើម្បីប្រមូលពង**

**ចំណាំ**

- ត្រូវចងចាំថាការថយចុះក្នុងការផលិតស៊ុត ប៉ះពាល់ដល់ចំណូលកសិករ ហើយប្រសិនបើវាកើតឡើងដោយចៃដន្យ មិនងាយនឹងធ្វើឱ្យត្រឡប់មកដូចដើមទេ ។
- អនុវត្តការងារឱ្យទៀងទាត់ជាមួយទាពងដូចជាការពិនិត្យទូទៅ និងគ្រប់គ្រងត្រឹមត្រូវធ្វើឱ្យកសិករទទួលជោគជ័យក្នុងការចិញ្ចឹមទាពង ។

## ២.៨ ការការពារជំងឺ

គួរចងចាំថា កសិករមិនអាចបង្កាត់ទា និងចិញ្ចឹមទាឱ្យមានសុខភាពល្អ ប្រសិនបើគេមិនចាប់ផ្តើមជាមួយទាដែលមានសុខភាពល្អ ។ ការព្យាបាលជំងឺ ជាទូទៅមានការលំបាក និងមានតម្លៃថ្លៃ ដូច្នេះជាការចាំបាច់ត្រូវធ្វើការការពារជំងឺកុំឱ្យកើតមាន ។ គោលការណ៍ខាងក្រោមនេះអាចជួយឱ្យការចិញ្ចឹមឃ្លាតឆ្ងាយពីជំងឺនានា ។

- ជានិច្ចជាកាលផ្តល់ចំណីដែលស្រស់ថ្មី មិនរលួយស្អុយ
- សំអាតស្នូកចំណី និងទឹក និងទ្រុងទាប្រចាំថ្ងៃ

- ✓ កុំឱ្យទាស្ថិតនៅក្រោមពន្លឺថ្ងៃខ្លាំង និងភ្លៀង (ជាពិសេសកូនទា)
- ✓ ទ្រុងទាត្រូវស្អាត និងមានខ្យល់ចេញចូលល្អ
- ✓ ចាក់ថ្នាំការពារជំងឺទាសំខាន់ៗទាន់ពេលវេលា និង
- ✓ យកទាឈឺចេញពីហ្វូង ។

**ចំណាំ**

- ✓ រកការជួយផ្តល់សេវាកម្មលើការចាក់ថ្នាំការពារដល់ទារបស់អ្នក ។

### ២.៨.១ ការចាក់ថ្នាំការពារជំងឺទា

ជំងឺទាមានច្រើនតែអាសន្នរោគ និងប៉េស្តទា ហើយតែងតែកើតនៅលើទានៅប្រទេសកម្ពុជាក្នុងពេលដែលទាមានអាយុប្រហែល ៦អាទិត្យ ឬនៅពេលដែលកូនទាចាប់ផ្តើមមានរោមពេញទ្រូងនៅពេលនេះវាត្រូវចាក់ថ្នាំការពារជំងឺអាសន្នរោគ និងប៉េស្តទា ។

**ជំងឺអាសន្នរោគទា**

នេះជាជំងឺដូចបង្កឡើងនៅលើមាន់ និងបក្សីដទៃទៀត ។ រោគសញ្ញានៃជំងឺមានៈ

- ✓ ទន់ខ្សោយ
- ✓ កំដៅឡើង
- ✓ ហើមសន្លាក់ជើង
- ✓ ឈឺភ្នែក ឬហើមភ្នែក
- ✓ រាក និង
- ✓ ជួនកាលហើមក្បាល ។

ការស្លាប់អាចកើតឡើងមួយរំពេច ដោយមិនបង្កឱ្យឃើញរោគសញ្ញាច្បាស់លាស់ ឬក៏ឃើញទាឈឺច្រើនថ្ងៃ ។ ប្រសិនបើវះកាត់ទាឈឺមួយក្បាលដែលងាប់រួចហើយនោះ នឹងពិនិត្យឃើញ ថ្លើមរីកធំពណ៌ស្លេកស្លាំង និងមានពណ៌អុចប្រផេះជាច្រើននៅលើនោះ ។ចូរចាក់ថ្នាំការពារទារបស់អ្នកប្រឆាំងនឹងជំងឺនេះ។ ប្រឆាំងជំងឺផ្ទុះឡើងនៅលើទាដែលមិនទាន់ចាក់ថ្នាំការពារអាចប្រើថ្នាំក្រុមពពួកស៊ុលហ្វាដើម្បីព្យាបាល ។ ថ្នាំនេះប្រើវា ដោយលាយជាមួយទឹកឱ្យទាផឹកហើយបរិមាណទឹកថ្នាំអាស្រ័យលើកំណត់ហេតុសរសេរនៅលិខិតក្នុងសំបុត្រថ្នាំ ។ កសិករចិញ្ចឹមទាត្រូវអនុវត្តតាមការណែនាំខាងក្រោមសម្រាប់ព្យាបាលទាៈ

- ✓ បង្ខាំងទាក្នុងទ្រុង
- ✓ មិនឱ្យទាផឹកទឹកក្នុងរយៈពេល ២-៣ម៉ោង ធ្វើឱ្យវាស្រេចទឹក
- ✓ បន្ទាប់មកទើបដាក់ទឹកលាយថ្នាំឱ្យវាផឹក និង
- ✓ ធ្វើតាមរបៀបនេះរយៈពេល ៣-៥ថ្ងៃ ។

វិធីមានប្រសិទ្ធិភាពត្រូវចាក់ថ្នាំការពារទាតាមអាយុរបស់វា។ កូនទាត្រូវចាក់ថ្នាំការពារជំងឺនេះ តាមអាយុដូចមានខាងក្រោមៈ

- ✓ ចាក់លើកទីមួយនៅពេលទាមានអាយុ១-១,៥ខែនៅពេលទាមានរោមពេញខ្លួនដោយចាក់ក្រោមស្បែក
- ✓ ១៥ថ្ងៃ ក្រោយត្រូវចាក់ជាលើកទី ពីរ និង
- ✓ ក្រោយមកទៀត ទាត្រូវចាក់ក្នុងមួយឆ្នាំម្តង ។

**វិធីធ្វើតេស្ត**

រោគសញ្ញានៃជំងឺនេះ ប្រហាក់ប្រហែលនឹងជំងឺអាសន្នរោគទាដែរ ហើយតែងតែច្រឡំគ្នា ប៉ុន្តែមានរោគសញ្ញាមួយចំនួន ខុសគ្នាដែលកសិករអាចរកឃើញបានៈ

- ✓ ទាទន់ខ្សោយដោយគ្មានឃើញហើមសន្លាក់ ឬឡើងកំដៅ
- ✓ មានចេញទឹកភ្នែកជាប់ ហើយរោមជុំវិញភ្នែកមានជាប់ពពឹកភ្នែក
- ✓ មានហៀរសំបោរ និង
- ✓ រាគរូស

ទាងាប់ក្នុងរយៈពេល ៣ថ្ងៃក្រោយពេលចាប់ផ្តើមឈឺ ។ ប្រសិនបើវះមិនមើលឃើញមានសញ្ញានៃជំងឺនោះទេតែបើយកបេះដូងទៅពិនិត្យឃើញមានឈាមជាំតូចៗនៅលើសាច់ដុំបេះដូងហើយកោះវិញ មើលទៅជាំខ្មៅ ។

**ចំណាំ**

- ✓ គ្មានថ្នាំសម្រាប់ព្យាបាលជំងឺនេះទេ
- ✓ ប្រសិនបើទិញទាមកពីខាងក្រៅ ទុកវាយ៉ាងហោចណាស់ ៣អាទិត្យ និងពិនិត្យតាមដានរោគសញ្ញា នៃជំងឺ មុននឹងបញ្ចូលវាជាមួយទាហ្វូងដែលមានស្រាប់នៅផ្ទះ ។

នៅពេលទាមានអាយុ ៧អាទិត្យត្រូវចាក់ថ្នាំការពារជំងឺនេះជាលើកទីមួយ ដោយចាក់ចូលក្នុងសាច់ដុំ ។ ទានឹងមានភាពស៊ាំក្នុងជីវិតរបស់វាដោយមិនចាំបាច់ចាក់ថ្នាំការពារជំងឺនេះ ជាលើកទី២ទៀតទេ ។

## ២.៩ ផលប្រយោជន៍សេដ្ឋកិច្ច

ការសន្មត់នានាប្រើប្រាស់សម្រាប់ការគណនាផលប្រយោជន៍សេដ្ឋកិច្ច មានដូចខាងក្រោមនេះ

- ការផ្តល់ចំណីបន្ថែមលើចុងអង្ករសម្រាប់កូនទា និងស្រូវសម្រាប់ទាពេញវ័យ ។

- កសិករត្រូវចំណាយថវិកា សម្រាប់ការសាងសង់ទ្រុងសម្រាប់កូនទា និងទ្រុងសម្រាប់ទាធំ និងមេទាពង មាននៅក្នុងការចិញ្ចឹមជាលក្ខណៈបុរាណ ក៏ដូចជានៅក្នុងបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះដែរ ។ ដូចនេះ តម្លៃសាងសង់ទ្រុងត្រូវដាក់បញ្ចូលសម្រាប់ការគណនាសេដ្ឋកិច្ចនៃប្រព័ន្ធទាំងពីរ។ តែបន្ថែមលើនេះដោយសារជំងឺផ្តាសាយបក្សី កសិករនឹងវិនិយោគបន្ថែមលើការសាងសង់ប្រព័ន្ធជីវសន្តិសុខសម្រាប់ទា ។
- ការវិភាគនេះ ប្រៀបធៀបតែលើផលចំណេញនៃការកែលំអចំណី និងការគ្រប់គ្រង ។ ដូចនេះបញ្ហាពាក់ព័ន្ធលើសុខភាព មិនបានសង្កត់ធ្ងន់នៅក្នុងការវិភាគនេះទេដោយសន្មត់ថា ទាចិញ្ចឹមនៅក្នុងប្រព័ន្ធទាំងពីរបានទទួលការចាក់ថ្នាំការពារជំងឺរួចរាល់ទៅហើយ ។
- ការគណនាផ្អែកទៅលើចំនួនទា ៣០-៣៥ក្បាលដែលកសិករខ្នាតតូចនិយមចិញ្ចឹម។ តែអាចបង្កើនចំណូលកាន់តែច្រើនសម្រាប់កសិករដែលមានធនធាន ដោយបង្កើនចំនួនទាដល់ ១០០-១៥០ ក្បាលដើម្បីប្រើប្រាស់កំលាំងពលកម្មគ្រួសារឱ្យមានប្រសិទ្ធិភាព ។
- ដើម្បីគណនាផលប្រយោជន៍សេដ្ឋកិច្ច មធ្យមភាគនៃការស៊ីចំណីរបស់ទាចាប់ផ្តើមពីកូនរហូតដល់មេទាពង ផ្អែកលើបទពិសោធន៍នៅសែលអាគ្រីត ត្រូវបានប្រើប្រាស់សម្រាប់ការគណនានេះ ។
- គោលបំណងនៃការកែលំអការផ្តល់ចំណី និងគ្រប់គ្រងទាដើម្បីបង្កើនអាត្រារស់របស់កូនទាការលូតលាស់ និងការរៀបចំទាសម្រាប់ទុកយកពង ។ សំរេចបានកត្តាទាំងនេះធានាឱ្យកូនទេលូតលាស់ឆាប់រហ័សនិងក្លាយជាមេទាពងដ៏ល្អ ។

**ឧទាហរណ៍ ប្រៀបធៀបសេដ្ឋកិច្ចនៃការចិញ្ចឹមតាមលក្ខណៈបុរាណនិងការកែលំអចំណីនិងគ្រប់គ្រងទាក្នុងមួយឆ្នាំក្នុងមួយគ្រួសារ**

| | ទំលាប់កសិករ | | | កែលំអ | | |
|---|---|---|---|---|---|---|
| ប្រាក់ចំណូល | ទិន្នផល ឯកតា/ឆ្នាំ | តម្លៃ រៀល/ឯកតា | ចំណូល រៀល/ឆ្នាំ | ទិន្នផល ឯកតា/ឆ្នាំ | តម្លៃ រៀល/ឯកតា | ចំណូល រៀល/ឆ្នាំ |
| មេទាពង | ៣០ក្បា | ១២០០០ | ៣៦០០០០ | ៣០ក្បា | ១២០០០ | ៣៦០០០០ |
| ផលិតកម្មស៊ុត | ២១០០គ្រាប់ | ៤៥០ | ៩៤៥០០០ | ៤៥០០គ្រាប់ | ៤៥០ | ២០២៥០០០ |
| | | សរុប | ១៣០៥០០០ | | | ២៣៨៥០០០ |
| ការចំណាយ | បរិមាណ ឯកតា/ឆ្នាំ | តម្លៃ រៀល/ឯកតា | ចំណាយ រៀល/ឆ្នាំ | បរិមាណ ឯកតា/ឆ្នាំ | តម្លៃ រៀល/ឯកតា | ចំណាយ រៀល/ឆ្នាំ |
| កូនទា | ៣៥ក្បាល | ៥៥០ | ១៩២៥០ | ៣៥ក្បាល | ៥៥០ | ១៩២៥០ |
| **ប្រើប្រាស់ចំណីក្នុងតារាងទីមួយ** | | | | | | |
| ស្រូវ | ៧៤៨ | ៥៥០ | ៤១១៤០០ | | | |
| ចុងអង្ករ | ២២១ | ៨០០ | ១៧៦៨០០ | ៤៦០ | ៨០០ | ៣៦៨០០០ |
| កន្ទក់ | | | | ៧២០ | ៥៥០ | ៣៩៦០០០ |
| ពោត | | | | ១៤២ | ៥៥០ | ៧៨១០០ |
| ម្សៅមើមដំឡូងឈើ | | | | ៥៥៣ | ៣៥០ | ១៩៣៥០ |
| ម្សៅត្រី | | | | ៨០ | ២០០០ | ១៦០០០០ |
| សណ្ដែកសៀង | | | | ១១ | ១៧០០ | ១៨៧០០ |
| ត្រកួន | | | | ១៧៩ | ១០០ | ១៧៩០០ |
| អំបិល | | | | ២០ | ៤០០ | ៨០០០ |
| ម្សៅសំបកខ្យង | | | | ១០ | ៤០០ | ៤០០០ |
| វ៉ាក់សាំង | ១៤០ | ១០០ | ១៤០០០ | ១៤០ | ១០០ | ១៤០០០ |
| ទ្រុង (៣០%)8 | | | ៩០០០០ | | | ៩០០០០ |
| របងជីវសន្តិសុខ | | | | | | ១៥០០០០ |
| | | ចំណាយប្រាក់សរុប | ៦៣០៤៥០ | | | ១៣៤៣៣០០ |
| **ប្រាក់ចំណេញ+ពលកម្ម** | | | ៦៧៤៥៥០ | | | ១០៤១៧០០ |
| **ចំណាយមិនមែនសាច់ប្រាក់** | | | | | | |
| ពលកម្ម | ១១៣ | ៤០០០ | ៤៥២០០០ | ៦៧ | ៤០០០ | ២៦៨០០០ |
| | | **ចំណាយសរុប** | ១០៨២៤៥០ | | | ១៦១១៣០០ |
| | | **ប្រាក់ចំណេញ** | ២២២៥៥០ | | | ៧៧៣៧០០ |
| | | **ប្រាក់ទទួលបានគិតជាពលកម្មក្នុងមួយថ្ងៃ** | ៥៩៧០ | | | ១៥៥៤៥ |

| | |
|---|---|
| ប្រាក់ចំណេញសុទ្ធ | ៥៥១១៥០ |
| បង្កើនចំណូលគ្រួសារ | ៣៦៧១៥០ |

*យើងគិតថាទ្រុងទាមួយដែលបានសាងសង់ អាចប្រើប្រាស់រយៈពេល ៣ឆ្នាំ ។

**ផលប៉ះពាល់លើបរិស្ថាន**

ដោយសារបច្ចេកវិទ្យាដែលបានលើកនៅក្នុង បអប ”TIP” នេះត្រូវបានគ្រប់គ្រងតាមលក្ខណៈធម្មជាតិដោយប្រើប្រាស់ផលនិងអនុផលកសិកម្ម ឬអ្វីដែលគាត់ផលិតហេតុដូច្នេះហើយធ្វើឱ្យមានផលប៉ះពាល់វិជ្ជមានមួយចំនួនសម្រាប់បរិស្ថាន ។

ទាចិញ្ចឹមក្នុងទ្រុងនៅកន្លែងមួយអាចប្រមូលលាមកសម្រាប់ដំណាំនិងក្នុងពេលជាមួយគ្នាអនុវត្ត ជីវសន្តិសុខដែលចូលរួមចំណែកក្នុងការការពារជំងឺទារួមបញ្ចូលទាំង ជំងឺផ្តាសាយបក្សី និងការពារមាន់មិនឱ្យទាបំផ្លាញសួនបន្លែកសិករដទៃ ។

ការចិញ្ចឹមជន្លេនជាវិធីមួយមានប្រសិទ្ធិខ្ពស់ណាស់ក្នុងការប្រើប្រាស់លាមកសត្វដែលមានអាសូតខ្ពស់ឱ្យក្លាយជាជីមួយមានជីជាតិជីវលាយឃីត១សម្រាប់ដំណាំ។ វិធីនេះអាចកាត់បន្ថយផលអាក្រក់ដល់បរិស្ថានដោយសារមានជីជាតិច្រើនបានភាយចេញពីប្រព័ន្ធកសិដ្ឋាន និងធ្វើឱ្យស្រះ ទន្លេ ពុលក្រខ្វក់ ។ល។ តែនឹងផលិតអាហារមួយដែលមានប្រូតេអ៊ីនយ៉ាងល្អ ។

## ៣. ការណែនាំលើការខារផ្សព្វផ្សាយ

### ៣.១ វិធីសាស្ត្រនៃការផ្សព្វផ្សាយ

ទាស្ថិតចំណោមសត្វនិយមចិញ្ចឹមដោយកសិករនៅជនបទ ហើយកសិករជាទូទៅទិញកូនទាពីទីផ្សារដែលមានអាយុមួយថ្ងៃ ។ កសិករមួយចំនួនភ្ញាស់កូនទាដោយមេមាន់ ឬទាកាប៉ា ។ ជាផលប្រយោជន៍លើកត្តា ឆ្លងជំងឺសំណូមពរឱ្យកសិករផលិតកូនទាដោយខ្លួនឯង ហើយអ្នកផ្សព្វផ្សាយអាចយកកូនទាដែលភ្ញាស់ទាំងនោះមកធ្វើការបង្ហាញ ។ កម្មវិធីផ្សព្វផ្សាយ ត្រូវរៀបចំឡើងជាមួយកសិករដែលមានបទពិសោធន៍ និងមានការចាប់អារម្មណ៍នៅក្នុងភូមិនៅទីតាំងផ្សេងៗក្នុងភូមិដែលអាចឱ្យកសិករផ្សេងរៀនសូត្រតាម ។ កសិករចូលរួមធ្វើបង្ហាញធ្វើកិច្ចសន្យាក្នុងការចែករំលែក និងអនុវត្តការបង្ហាញនេះជាមួយកសិករដៃគូររបស់គេ៥នាក់ទៀតភ្នាក់ងារផ្សព្វផ្សាយ ជួបប្រជុំជាមួយក្រុមកសិករនេះរៀងរាល់សប្តាហ៍ដើម្បីពិនិត្យតាមដានការធ្វើបង្ហាញ នេះហើយជាមួយគ្នានោះដែរពិភាក្សាបញ្ហា ឬប្រធានបទពាក់ព័ន្ធនានា ទៅលើការអនុវត្តន៍ បអប ’TIP’ នេះ ។

វិធីសាស្ត្រសម្រាប់ការអនុវត្តន៍ បអប ’TIP’នេះផ្អែកលើការធ្វើបង្ហាញតាមគោលដៅគ្រួសារនីមួយៗ ប៉ុន្តែការជួបប្រជុំ និងពិភាក្សារៀងរាល់សប្តាហ៍ត្រូវធ្វើជាក្រុមធំនៅក្នុងភូមិដែលមានការចូលរួមទាំងកសិករធ្វើ បង្ហាញ និងដៃគូរបស់គេ ។

ដ្យាក្រាមនៃយុទ្ធសាស្ត្រីកសាយលើការងារផ្សព្វផ្សាយនៃ TIP នេះ




**ដំណាក់កាល និងការណែនាំ**

ដំណាក់កាល និងបែបបទនានាក្នុងការរៀបចំអនុវត្ត និងវាយតម្លៃទៅលើ បអប ’TIP’ នេះ មានរៀបចំក្បោះក្បាយនៅខាងក្រោមះ

<u>**ការជ្រើសរើសទីតាំង**</u>

ដោយសារតែ បអប ‘TIP’ នេះ អាចសមស្របស្ទើរតែគ្រប់តំបន់ទាំងអស់នៃប្រទេសកម្ពុជា ដូច្នេះមិនមានជាលក្ខណៈវិនិច្ឆ័យអ្វីធំដុំសម្រាប់ការជ្រើសរើសនោះឡើយ។ ទោះបីយ៉ាងនេះក៏ដោយភូមិដែលមានផ្ទះនៅដាច់ៗ ឆ្ងាយពីគ្នាគួរត្រូវបានជ្រើសរើសដើម្បីសាកល្បង ’TIP’ នេះជាដំបូងសិនដើម្បីងាយស្រួលក្នុងការរៀបចំ និងទីកន្លែងសម្រាប់ផលិតចំណីទាទៀតផង ។

<u>**ការជ្រើសរើសកសិករ និងការរៀបចំ**</u>

ដើម្បីធ្វើឱ្យតម្លៃ ការងារផ្សព្វផ្សាយនេះអាចទទួលយកបាន និងបង្កើនប្រសិទ្ធិភាពនៃការប្រើធនធាននោះភ្នាក់ងារផ្សព្វផ្សាយគួរះ

- ជ្រើសរើសកសិករចាប់អារម្មណ៍ និងសកម្ម ៥-១០នាក់ នៅក្នុងភូមិមួយ (ចំនួនអាស្រ័យលើចំនួនគ្រួសារដង់ស៊ីតេ និងទំហំភូមិ) ។ កសិករចូលរួមត្រូវចាប់ផ្តើមយ៉ាងហោចណាស់ ៣០-៣៥ទា សម្រាប់ចូលរួមអនុវត្ត 'TIP' នេះ ។
- កសិករដែលបានជ្រើសរើសមានផ្ទះនៅឆ្ងាយៗពីគ្នានៅក្នុងភូមិ ដើម្បីធ្វើឱ្យការផ្សព្វផ្សាយចែកចាយដល់មនុស្សច្រើន ។ កសិករចូលរួមធ្លាប់មានបទពិសោធន៍លើការចិញ្ចឹមមាន់ខ្លះ និងមានចិត្តចង់ចូលរួម ។
- ជាលក្ខខណ្ឌសម្រាប់ចូលរួមនៅក្នុងការអនុវត្តន៍ 'TIP' នេះកសិករដែលបានជ្រើសរើសត្រូវរកដៃគូរចំនួន ៥នាក់ ដែលរស់នៅជុំវិញផ្ទះខ្លួនដើម្បីធ្វើការរៀនសូត្ររួមគ្នា ។
- ដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់កសិករជ្រើសរើស និងចែករំលែកបទពិសោធន៍ដល់អ្នកដទៃ មានសំភារៈមួយចំនួនដែលផ្តល់ឱ្យកសិករដូចជាវត្ថុធាតុផ្សំចំណី ដែលគាត់មិនអាចផលិតនៅក្នុងភូមិ និងពូជដំណាំជាចំណីប្រូតេអ៊ីន ឬប្លាស្ទិកសម្រាប់ផលិតចកបាយទា ក្នុងករណីលក្ខខណ្ឌអំណោយផល និងវ៉ាក់សាំង ប៉ុន្តែកសិករត្រូវមានកូនទា សំភារៈសម្រាប់ធ្វើទ្រុង របងបាំង និងដី ។

**ឧបករណ៍/សំភារៈ**

សំភារៈដែលមិនមាននៅក្នុងភូមិ ឬមិនអាចផលិតបានដោយកសិករ អាចត្រូវផ្តល់ឱ្យជាការលើកទឹកចិត្តដើម្បីចូលរួមនិងចែករំលែកបទពិសោធន៍ដល់អ្នកដទៃ ។ សំភារៈ និងឧបករណ៍ត្រូវការសម្រាប់អនុុវត្តបអប 'TIP' នេះមានៈ

**សំភារៈឧបត្ថម្ភដល់កសិករ**

- វ៉ាក់សាំងសម្រាប់ចាក់ការពារជំងឺ (អាសន្នរោគ និងប៉េស្ត) សម្រាប់ការធ្វើបង្ហាញប៉ុណ្ណោះ ។
- កំរាលប្លាស្ទិកប្រសិនបើកសិករត្រូវការផលិតចកបាយទា ។
- ចំណីប្រូតេអ៊ីនដែលកសិករមិនអាចផលិតបានដោយខ្លួនឯង (ផ្តល់លើកដំបូងជាការលើកទឹកចិត្ត) ។
- គ្រាប់ពូជដំណាំចំណីសត្វរួមបញ្ចូលទាំងជន្លេន ប្រសិនបើ មានតំរូវការ ។

**ចំណាំ**

- ✓ ដើម្បីអនុវត្តន៍បអប 'TIP' នេះជាលក្ខណៈទ្រង់ទ្រាយធំដែលមានកសិករច្រើនចាប់អារម្មណ៍ នោះចំណាយផ្សេងៗត្រូវចេញដោយកសិកររួមទាំងតម្លៃសេវាកម្មក្រោយពី ការធ្វើបង្ហាញម្តង ។
- ✓ ភ្នាក់ងារផ្សព្វផ្សាយនៅពេលនោះ អាចធ្វើការជាមួយភ្នាក់ងារពេទ្យសត្វភូមិ ប្រសិនបើមាន ដើម្បីជួយសំរួលដល់ការអនុវត្តន៍ 'TIP' នេះ ។ ជាទូទៅកសិករមិនមានប្រាក់សម្រាប់បង់ដល់សេវាកម្មរបស់ភ្នាក់ងារផ្សព្វផ្សាយ ក៏ដូចជាពេទ្យសត្វភូមិដែរ ដូច្នេះភាគីទាំងសងខាង

ត្រូវរៀបចំជាកិច្ចព្រមព្រៀងដោយយកថ្លៃ សេវាកម្ម និងថ្លៃរ៉ាក់សាំង ពី៣-៥% នៃតម្លៃស៊ុតសរុបដែលបានផលិត ។

✓ ធ្វើតាមវិធីនេះ អាចលើកទឹកចិត្តទាំងកសិករ ភ្នាក់ងារផ្សព្វផ្សាយ និងពេទ្យសត្វភូមិអនុវត្តឱ្យល្អដើម្បីចែកចាយផលប្រយោជន៍គ្នា ។

**<u>ការចូលរួមចំណែកពីកសិករ</u>**

- រៀបចំដីមួយផ្នែកសម្រាប់អនុវត្ត 'TIP' នេះ ។
- មានកូនទា ៣០-៣៥ក្បាល សម្រាប់អនុវត្ត 'TIP' នេះ ។
- សំភារៈសម្រាប់សាងសង់ទ្រុង ដំបូល និងរបងបិទបាំង ។
- សមាជិកគ្រួសារម្នាក់ទទួលខុសត្រូវលើការងារនេះរួមបញ្ចូលទាំងការចូលរួមនៅក្នុងកិច្ចប្រជុំនិងពិភាក្សាគ្នានានា ។
- ចំណីទា មាន ចុងអង្ករ និងកន្ទក់ដើម្បីផ្សំចំណីតាមរូបមន្តខាងលើ ។

**<u>ការពិនិត្យតាមដាន និងវាយតម្លៃ</u>**

ភ្នាក់ងារផ្សព្វផ្សាយ ត្រូវចុះជួបកសិករដល់ទីកន្លែងឱ្យញឹកញាប់នៅពេលកូនទានៅតូច ។ តួនាទីអ្នកផ្សព្វផ្សាយដែលត្រូវធ្វើមានដូចខាងក្រោមៈ

- រៀបចំការប្រជុំជាមួយកសិករ និងដៃគូររបស់ពួកគេ ដើម្បីពិភាក្សាលើដំណើរការបង្ហាញអាស្រ័យ ទៅតាម ជម្រើសបច្ចេកទេសដែលកសិករបានជ្រើស ។
- ពិនិត្យតាមដាននៅតាមផ្ទះនីមួយៗដើម្បីវាយតម្លៃទៅលើការអនុវត្តន៍ 'TIP' នេះ ។
- ថ្លឹងកូនទាជាក្រុមរៀងរាល់ ១០ថ្ងៃម្តង ជាមួយម្ចាស់ ។
- រៀបចំការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួមពីកសិករនៅពេលកូនទាមានអាយុ៣ខែ (ដំណាក់កាលលូតលាស់) ។ នៅថ្ងៃជាមួយគ្នានេះ ភ្នាក់ងារផ្សព្វផ្សាយអាចអញ្ជើញកសិករផ្សេងៗទៀតឱ្យចូលរួមវាយតម្លៃ 'TIP' នេះ និងទន្ទឹមគ្នានោះរៀបចំទិវាស្រែកសិករដែលអនុញ្ញាតឱ្យកសិករបង្គោលចែករំលែក បទពិសោធន៍ដល់អ្នកដទៃ ។ នៅដំណាក់កាលដែលទាចាប់ផ្តើមពង ភ្នាក់ងារផ្សព្វផ្សាយអាចកាត់បន្ថយពេលវេលាក្នុងការចុះជួបជាមួយកសិករតែនៅពេលចុះម្តងៗ ភ្នាក់ផ្សព្វផ្សាយតាមដានការផលិតស៊ុតរបស់ទា ហើយអាចមានរៀបចំប្រធានបទណាមួយពាក់ព័ន្ធលើដំណាក់កាលផលិតកម្មស៊ុតនេះ ។

**ផែនការ**

ចំពោះ 'TIP' នេះ មិនមានពេលវេលា/រដូវជាក់លាក់ចាំបាច់នោះទេ តែជាការប្រសើរគួរតែចាប់អនុវត្ត នៅដើមរដូវភ្លៀងធ្លាក់ ដោយសារមានទឹកសម្រាប់កូនទាហែលលេង និងមានចំណីអាហារធម្មជាតិដូចជា ត្រកួន កូនក្តាម ខ្យង ។ល។

### ៣.២ ថវិកាសំរាប់ការធ្វើបង្ហាញ

ថវិកាសម្រាប់កម្មវិធីផ្សព្វផ្សាយ នឹងប្រែប្រួលអាស្រ័យលើតម្រូវការជាក់ស្តែងនៃសាម៊ីអង្គភាព ។ តារាងថវិកាខាងក្រោមបានបង្កើតឡើងក្នុង ឆ្នាំ២០០៦ ដោយយោងទៅលើការប៉ាន់ស្មានលើបទដ្ឋានអនុវត្ត បច្ចេកវិទ្យារបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

| **ថវិកា និង ការសន្មត់** | ចំនួន / តម្លៃ |
|---|---|
| ក្រុមកសិករ (ក) | ៣០ នាក់ |
| ទុនសម្រាប់ទីតាំងធ្វើបង្ហាញ (ខ) | $១៣៥ |
| ការបណ្តុះបណ្តាលក្រុមកសិករ (គ)<br>- ឯកសារ ឬ ការណែនាំពីបច្ចេកវិទ្យា បអប | $៣០ |
| ការបណ្តុះបណ្តាលក្រុមកសិករ (ឃ)<br>- អាហារសំរ៉ន់ | $៩០ |
| ទុនចូលរួមពីកសិករគំរូ (ង) | កំលាំងពលកម្ម ទីកន្លែង-សំភារៈ កូនទា ពេទ្យសត្វភូមិ |
| ទិវាស្រែ — អាហារសំរ៉ន់ (ច) | $២៥ |
| ទិវាស្រែ — សំភារៈ (ឆ) | $១០ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ (ជ)<br>- ការបណ្តុះបណ្តាល ការត្រួតពិនិត្យទីកន្លែងធ្វើបង្ហាញ | $៤២ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភ ថ្លៃធ្វើដំណើរ (ឈ) | $២៤ |
| ការចុះត្រួតពិនិត្យ-តាមដាននៅមូលដ្ឋានដោយអ្នកឯកទេសជំនាញ (ញ) | $២០ |
| សរុប | **$៣៧៦** |

**ការសន្មត់ប្រើប្រាស់មាន**

ក. ក្នុង បអប មួយ មានក្រុមកសិករ (៣០ នាក់) និងកសិករគំរូ ដែលមានទីកន្លែងបង្ហាញ ៣ កន្លែង

ខ. ទុនសម្រាប់ទីតាំងធ្វើបង្ហាញ កូនទា៣៥ក្បាល x ៣បង្ហាញ x US$0,២ = US$ ២១

- ម្សៅត្រី (២៧គក្រ x ៣បង្ហាញ x US$0,៥= US$4៤0,៥ប + សណ្តែកសៀង (៤ គក្រ x ៣បង្ហាញ x US$0,៤= US$4៤,៨ប + គ្រាប់ជូជត្រកួនសំរាប់ដាំធ្វើចំណី (២ គក្រ x ៣បង្ហាញ x US$១,៥ US$៩ប = US$៥៤,៣
- ទ្រុង (សំណាញ់) ៣បង្ហាញ x US$២0 = US$៦0 .

សរុបទុនសម្រាប់ទីតាំងបង្ហាញទាំងអស់គឺ US$១៣៥

គ. ឯកសារបណ្តុះបណ្តាលបច្ចេកវិទ្យាមានរួមបញ្ចូលទាំងសំភារៈសម្រាប់បង្រៀន មេរៀន ការបញ្ចាំងស្លាយ និង ផ្ទាំងរូបភាពធំៗ ដែលជាដំណើរការនៃវិធីសាស្រ្តបង្រៀន ។

ឃ. ការបណ្តុះបណ្តាលក្រុមកសិករមាន ៣វគ្គ មួយវគ្គ មានរយៈពេលមួយថ្ងៃ លើកលែងតែវគ្គ ការធ្វើជីកំប៉ុស្តិ៍ មានតែ ២វគ្គទេ និង ការកំណត់ចំណាត់ថ្នាក់ដី មានមួយវគ្គដែរ

ង. ទុនចូលរួមពីកសិករឬទីកន្លែងបង្ហាញ មានដីសំរាប់អនុវត្ត មានកូនទា ៣0-៣៥ក្បាល កំលាំងពលកម្ម សំភារៈសម្រាប់សាងសង់ទ្រុង ដំបូល និងរបងបិទបាំង និងកន្ទក់ដើម្បីផ្សំចំណី កំលាំងពលកម្ម និង ថវិកាសម្រាប់ពេទ្យសត្វភូមិ ។

ច. ទិវាស្រែមានកន្លះថ្ងៃ មានតែម្តងក្នុងវគ្គណាមួយក្នុងចំណោមទាំងបីវគ្គ និងអាចមានការចូលរួមពីកសិករនៅក្បែរៗភូមិប្រហែល ៤0-៦0នាក់ ។

ឆ. សំភារៈសម្រាប់ទិវាស្រែរួមមានឧឃោសនស័ព្ទ(មេក្រូ) កំរាលប្លាស្ទិក និងផ្ទាំងបដារូបភាពផ្សេងៗ ទៀត

ជ. សម្រាប់មន្ត្រីកសិកម្មស្រុក ថវិកាឧបត្ថម្ភរួមមាន៤ថ្ងៃ សម្រាប់ការជ្រើសរើសទីកន្លែងបង្ហាញ ការចាប់ផ្តើម ការត្រួតពិនិត្យតាមដាន ។ ចំពោះការបណ្តុះបណ្តាលសម្រាប់ ៣វគ្គ ផ្តល់អោយ ៦ ថ្ងៃ និងទិវាស្រែផ្តល់ អោយ២ថ្ងៃ

ឈ. ប្រាក់ឧបត្ថម្ភសម្រាប់ម៉ូតូ ២ដុល្លាសម្រាប់មួយថ្ងៃ ទាំងអស់ ១២ថ្ងៃ

ញ. មន្ទីរកសិកម្មខេត្ត-អ្នកឯកទេសផ្តល់ជំនួយបច្ចេកទេស និងត្រួតពិនិត្យ-តាមដានការបណ្តុះបណ្តាល បអប

## ៣.៣ កន្លែងរកឯកសារបន្ថែម

មជ្ឈមណ្ឌលអភិវឌ្ឍន៍ការចិញ្ចឹមសត្វ និងកសិកម្ម “សែលអាគ្រីត “ www.celagrid.org និង នាយកដ្ឋាន ផលិតកម្ម និងបសុព្យាបាល ។

### ៣.៤ យែនឌ័រ

ស្ត្រីសមរម្យសម្រាប់ជ្រើសរើសក្នុងការចូលរួមនៅក្នុង បអប 'TIP' នេះ ដោយសារជាទូទៅពួកគេ ច្រើនធ្វើការងារនៅក្បែរផ្ទះ។ 'TIP' នេះអាចជួយស្ត្រីឱ្យបង្កើនចំណូល ដើម្បីគាំទ្រដល់គ្រួសារគេជាពិសេសសម្រាប់បង្កើនអាហាររូបត្ថម្ភដល់កុមារ និងទិញសំភារៈសម្រាប់កូនទៅសាលារៀន ។

ដោយសារអ្នកចូលរួមអនុវត្ត 'TIP' នេះ ភាគច្រើនជាស្ត្រីការផ្តល់អទិភាពដល់អ្នកផ្សព្វផ្សាយជាស្ត្រីក្នុងការរៀបចំការងារនេះនៅតាមភូមិមានសារៈសំខាន់ណាស់ ។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង**

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ២០០ វិថីព្រះនរោត្តម ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: ០១២ ៨៣៣ ៧៧៧ ឬ ០១២ ៨២៦ ៦១៧

ទូរសារ: ៨៥៥ ២៣ ២១០ ៩៤៨ ឬ ៨៥៥ ២៣ ២១៣ ០១១

អ៊ីម៉ែល: kunso@camnet.com.kh ឬ mak_soeun@camnet.com.kh